# សេចក្តីប្រកាសអាស៊ានស្តីពីតួនាទីរបស់មុខងារសាធារណៈ ជាកាតាលីករឈានទៅសម្រេចបាននូវចក្ខុវិស័យអាស៊ាន ឆ្នាំ ២០២៥

**យើង** ប្រមុខនៃរដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ដែលរួមមាន ប្រទេសប្រ៊ុយណេដារូសាឡឹម ព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋឥណ្ឌូនេស៊ី សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ម៉ាឡេស៊ី សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា សាធារណរដ្ឋហ្វីលីពីន សាធារណរដ្ឋសិង្ហបុរី ព្រះរាជាណាចក្រថៃ និងសាធារណរដ្ឋសង្គមនិយមវៀតណាម នៅក្នុងឱកាសនៃកិច្ចប្រជុំកំពូលអាស៊ាន លើកទី៣០ ឆ្នាំ២០១៧ នៅក្នុងទីក្រុងម៉ានីល ប្រទេសហ្វីលីពីន

**ដោយរំលឹក** ដល់សេចក្តីប្រកាសទីក្រុងកូឡាឡាំពួរ (**Kuala Lumpur**) ស្តីពីអាស៊ាន២០២៥: **Forging Ahead Together** (ឈានទៅមុខរួមគ្នា) ត្រូវបានអនុម័តក្នុងអំឡុងកិច្ចប្រជុំកំពូលអាស៊ានលើកទី២៧ នៅក្នុងទីក្រុងកូឡាឡាំពួរ (**Kuala Lumpur**) ប្រទេសម៉ាឡេស៊ី នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៥

**ដោយទទួលស្គាល់** អំពីសារៈសំខាន់នៃវិស័យមុខងារសាធារណៈ ដែលជាឆ្អឹងខ្នងនៃអភិបាលកិច្ចល្អ នៅក្នុងតំបន់ និងបេសកកម្មដ៏ចម្បងរបស់មុខងារសាធារណៈ មិនត្រឹមតែផ្តល់សេវាសាធារណៈចំបាច់ជូនប្រជាជនអាស៊ានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជំរុញការអភិវឌ្ឍន៍ជាតិ និងសង្គម ការគ្រប់គ្រងធនធានសាធារណៈប្រកបដោយការទទួលខុសត្រូវ ការដើរពីមុខការផ្លាស់ប្តូរ និងគ្រប់គ្រងទំនាក់ទំនងដែលមានការវិវត្តន៍រវាងរដ្ឋាភិបាល និងប្រជាជនថែមទៀតផង

**ដោយទទួលស្គាល់បន្ថែមទៀត** អំពីតួនាទីនៃវិស័យមុខងារសាធារណៈដែលជាកាតាលីករសម្រាប់ការលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរវិស័យ និងកិច្ចសហប្រតិបត្តិការឆ្លងកាត់សសរស្តម្ភ ក្នុងការកសាងសហគមន៍អាស៊ាន និងផ្តល់ការគាំទ្រឆ្ពោះទៅរកការធ្វើសមាហរណកម្មនៅក្នុងតំបន់បន្ថែមទៀត ស្របទៅតាមចក្ខុវិស័យអាស៊ាន ២០២៥ ព្រមទាំងលើកកម្ពស់ការយល់ដឹងអំពីអាស៊ាន

**ដោយទទួលស្គាល់** អំពីការចូលរួមចំណែករបស់វិស័យមុខងារសាធារណៈ ដល់ការឈានទៅសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពដោយរដ្ឋសមាជិកអាស៊ាន តាមរយៈការបន្តគំនិតផ្តួចផ្តើមឆ្ពោះទៅវិស័យមុខងារសាធារណៈប្រកបដោយស្តង់ដារមនសិការវិជ្ជាជីវៈខ្ពស់ ប្រសិទ្ធផល ប្រសិទ្ធភាព អភិក្រម ដែលមានការចូលរួមការទទួលខុសត្រូវ តម្លាភាព និងគណនេយ្យភាព

**ដោយបញ្ជាក់ជាថ្មី** ពីការប្តេជ្ញាចិត្តនៃមុខងារសាធារណៈរបស់រដ្ឋសមាជិកអាស៊ាន ក្នុងការគាំទ្រដល់ការធ្វើសមាហរណកម្មបន្ថែមទៀតរបស់សហគមន៍អាស៊ាន ដូចដែលបានចែងនៅក្នុងសេចក្តីប្រកាសរួមទីក្រុងពូត្រាចាយ៉ា (**Putrajaya**) ស្តីពី វិស័យអាទិភាពនានាក្រោយឆ្នាំ២០១៥ ឆ្ពោះទៅវិស័យមុខងារសាធារណៈ ដែលផ្តោតលើពលរដ្ឋអាស៊ាន ដែលត្រូវបានអនុម័តដោយប្រមុខមុខងារសាធារណៈ នៅទីក្រុង ពូត្រាចាយ៉ា (**Putrajaya**) ប្រទេសម៉ាឡេស៊ី នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៥

និងផែនការការងារ ACCSM ២០១៦-២០២០ ត្រូវបានអនុម័តដោយប្រមុខមុខងារសាធារណៈ នៅក្នុងទីក្រុងម៉ានីល ប្រទេសហ្វីលីពីន នៅខែវិច្ឆិកា ឆ្នាំ២០១៦

**នឹងយល់ព្រមខិតខំប្រឹងប្រែងដើម្បី ៖**

១. លើកកម្ពស់កិច្ចសហប្រតិបត្តិការនៅក្នុងការអភិវឌ្ឍន៍ និងការអនុវត្តកម្មវិធីការកសាងសមត្ថភាព និងការចែករំលែកឧត្តមានុវត្តន៍នៅក្នុងវិស័យពាក់ព័ន្ធសំខាន់ៗ ដូចជាការលើកកម្ពស់បរិស្ថានការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងគ្រោះមហន្តរាយ ការបន្ធូរបន្ថយ និងការឆ្លើយតប ការគ្រប់គ្រងសុខភាព សមភាពយេនឌ័រនៅក្នុងទីកន្លែងធ្វើការ អភិបាលកិច្ចល្អ ការគ្រប់គ្រងប្រជាជនប្រកបដោយវឌ្ឍនភាព គុណផលរបស់ស្ថាប័ន និងការចូលរួមរបស់មន្ត្រី ការទាក់ទាញអ្នកដែលមានទេពកោសល្យ និងការកសាងជំនាញនានាក្នុងវិស័យមុខងារសាធារណៈអាស៊ាន

២. លើកកម្ពស់ស្តង់ដារវិជ្ជាជីវៈ និងសមត្ថភាពរបស់មន្ត្រីរាជការនៅក្នុងវិស័យផ្សេងៗ និងកសាងសហគមន៍វិជ្ជាជីវៈនៅក្នុងវិស័យនីមួយៗ ដើម្បីជំរុញទំនាក់ទំនងរវាងវិស័យនានា ឲ្យកាន់តែមានភាពស្និទ្ធស្នាល និងមានកិច្ចសហការកាន់តែប្រសើរ

៣. ធានាថាវិស័យមុខងារសាធារណៈអាស៊ាន ប្រកាន់ខ្ជាប់គោលការណ៍អភិបាលកិច្ចល្អ រួមមានការយកប្រជាពលរដ្ឋជាស្នូល និងនវានុវត្តន៍ ព្រមទាំងចែករំលែកឧត្តមានុវត្តន៍ និងចំណេះដឹងនៅក្នុងវិស័យទាំងនេះ សម្រាប់ផលប្រយោជន៍ទៅវិញទៅមក ដើម្បីកសាងស្ថាប័នសាធារណៈនានាប្រកបដោយលក្ខណៈរឹងមាំ គួរអោយជឿទុកចិត្តបាន ត្រៀមខ្លួនជាស្រេចសម្រាប់ពេលអនាគត និងមានសមត្ថភាពក្នុងការដោះស្រាយរាល់បញ្ហាប្រឈមថ្មីៗ និងស្មុគស្មាញ

៤. ប្រកាន់ខ្ជាប់ និងការពារសុខុមាលភាពរបស់មន្ត្រីរាជការនៅក្នុងតំបន់ រួមបញ្ចូលអ្នកដែលចូលរួមសកម្មភាពក្នុងតំបន់ និងអ្នកដែលបំពេញតួនាទីសំខាន់ៗក្នុងពេលមានគ្រោះមហន្តរាយ និងស្ថានភាពប្រកបដោយគ្រោះថ្នាក់នានា និង

៥. ពង្រឹងការកសាងសម្ព័ន្ធភាព/បណ្តាញទំនាក់ទំនង/ភាពជាដៃគូ នៅក្នុងចំណោមរដ្ឋសមាជិកអាស៊ាន ក៏ដូចជា ជាមួយដៃគូសន្ទនាអាស៊ាន អង្គការក្នុងតំបន់និងពហុភាគី សង្គមស៊ីវិល វិស័យឯកជន និងអ្នកពាក់ព័ន្ធនានា ក្នុងការគាំទ្រការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវការប្តេជ្ញាចិត្ត ដែលមានចែង នៅក្នុងសេចក្តីប្រកាសនេះ។

យើងប្រគល់ភារកិច្ចជូន ACCSM ជាអ្នកដឹកនាំ ក្នុងកិច្ចសហការជាមួយអង្គភាពតាមវិស័យនៅក្រោមសហគមន៍នយោបាយ-សន្តិសុខអាស៊ាន (APSC) សហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) និងសហគមន៍សង្គម-វប្បធម៌អាស៊ាន (ASCC) ដើម្បីរៀបចំផែនការការងារមួយឆ្ពោះទៅសម្រេចឲ្យបាននូវបំណងប្រាថ្នាដែលមានចែងនៅក្នុងសេចក្តីប្រកាសនេះ។

ត្រូវបានចុះហត្ថលេខានៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីននៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៧ ដោយមានសំណៅដើមតែមួយគត់ជាភាសាអង់គ្លេស។

សម្រាប់ប្រទេសប្រ៊ុយណេដារូសាឡឹម ៖

……………………………………………

**H.E. HAJI HASSANAL BOLKIAH**

ស៊ុលតង់ នៃប្រទេសប្រ៊ុយណេដារូសាឡឹម

សម្រាប់ព្រះរាជាណាចក្រកម្ពុជា ៖

……………………………………………

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

នាយករដ្ឋមន្ត្រី

សម្រាប់សាធារណរដ្ឋឥណ្ឌូនេស៊ី ៖

……………………………………………

**H.E. JOKO WIDODO**

ប្រធានាធិបតី

សម្រាប់សាធារណរដ្ឋប្រជាមានិតឡាវ ៖

……………………………………………

**H.E. THONGLOUN SISOULITH**

នាយករដ្ឋមន្ត្រី

សម្រាប់ប្រទេសម៉ាឡេស៊ី ៖

……………………………………………

**H.E. DATO’ SRI MOHD NAJIB TUN ABDUL RAZAK**

នាយករដ្ឋមន្ត្រី

សម្រាប់សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា ៖

……………………………………………

**H.E. AUNG SAN SUU KYI**

ក្រុមប្រឹក្សារដ្ឋ

សម្រាប់សាធារណរដ្ឋហ្វីលីពីន ៖

……………………………………………

**H.E. RODRIGO ROA DUTERTE**

ប្រធានាធិបតី

សម្រាប់សាធារណរដ្ឋសិង្ហបុរី ៖

……………………………………………

**H.E. LEE HSIEN LOONG**

នាយករដ្ឋមន្រ្តី

សម្រាប់ព្រះរាជាណាចក្រថៃ ៖

……………………………………………

**H.E. GENERAL PRAYUT CHAN-O-CHA (RET.)**

នាយករដ្ឋមន្រ្តី

សម្រាប់សាធារណរដ្ឋសង្គមនិយមវៀតណាម ៖

……………………………………………

**H.E. NGUYEN XUAN PHUC**

នាយករដ្ឋមន្រ្តី

# ASEAN DECLARATION ON THE ROLE OF THE CIVIL SERVICE AS A CATALYST FOR ACHIEVING THE ASEAN COMMUNITY VISION 2025

**WE**, the Heads of the Member States of the Association of Southeast Asian Nations (ASEAN), consisting of Brunei Darussalam, the Kingdom of Cambodia, the Republic of Indonesia, the Lao People's Democratic Republic, Malaysia, the Republic of the Union of Myanmar, the Republic of the Philippines, the Republic of Singapore, the Kingdom of Thailand, and the Socialist Republic of Viet Nam, on the occasion of the 30$^{th}$ASEAN Summit 2017 in Manila, Philippines;

**RECALLING** the Kuala Lumpur Declaration on ASEAN 2025: Forging Ahead Together, adopted during the 27$^{th}$ ASEAN Summit in Kuala Lumpur, Malaysia on 22 November 2015;

**RECOGNISING** the significance of the civil service as the backbone of good governance in the region, and its critical mission not only in providing vital public services to the peoples of ASEAN, but also in driving national and social development, administering public resources responsibly, anticipating the changes ahead and managing the evolving relationship between the government and the people;

**FURTHER RECOGNISING** the role of the civil service as a catalyst for enhanced cross-sector and cross-pillar cooperation, in building the ASEAN Community, providing support towards furthering regional integration in accordance with the ASEAN Vision 2025, and promoting ASEAN awareness;

**ACKNOWLEDGING** the contribution of the civil service to the attainment of the Sustainable Development Goals by ASEAN Member States through continuing initiatives towards the highest standards of professionalism, efficiency, effectiveness, participatory approach, responsiveness, transparency and accountability of civil service;

**REAFFIRMING** the commitment of the civil services of ASEAN Member States in supporting further integration of the ASEAN Community as embodied in the Putrajaya Joint Declaration on Post 2015 Priorities - Towards an ASEAN Citizen Centric Civil Service, which was adopted by the Heads of Civil Service in Putrajaya, Malaysia on 17 November 2015; and the ASEAN Cooperation on Civil Service Matters (ACCSM) Work Plan 2016-2020 adopted by the Heads of Civil Service in Manila, Philippines on November 2016;

Do hereby agree to endeavor to:

i. Promote cooperation in the development and implementation of capacity-building programmes and share best practices in critical areas of concern such as environment promotion and climate change adaptation and mitigation; disaster management, mitigation and response; health management; gender equality in the workplace; good governance; progressive people management, organisational performance and employee engagement, talent attraction and skills building in the civil services of ASEAN;

ii. Raise the professional standards and capability of civil servants in different sectors, and build the community of professionals in each sector to forge closer ties and enable collaboration;

iii. Ensure that the civil services of ASEAN embrace good governance principles such as citizen-centricity and innovation, and share best practices and knowledge in these areas for mutual benefit, so as to build government institutions that are resilient, trusted and future-ready, and capable of addressing new challenges and complexities;

iv. Uphold and protect the welfare of civil servants in the region, including those engaged in intra-regional commitments and those performing critical roles in times of disaster and other hazardous situations; and

v. Strengthen alliance-building/networking/partnership among ASEAN Member States as well as with ASEAN Dialogue Partners, regional and multilateral organisations, civil society, private sector, and other stakeholders in supporting the effective implementation of the commitments reflected in this Declaration.

We task the ACCSM, as the lead, in collaboration with relevant sectoral bodies under the ASEAN Political and Security Community (APSC), ASEAN Economic Community (AEC) and ASEAN Socio-Cultural Community (ASCC) to develop a work plan towards realising the aspirations contained in this Declaration.

Done at Manila, the Philippines on the Twenty Ninth Day of April in the Year Two Thousand and Seventeen, in a single original copy in the English Language.

For Brunei Darussalam:

**HAJI HASSANAL BOLKIAH**
Sultan of Brunei Darussalam

For the Kingdom of Cambodia:

**SAMDECH AKKA MOHA SENA PADEI TECHO HUN SEN**
Prime Minister

For the Republic of Indonesia:

**JOKO WIDODO**
President

For the Lao People's Democratic Republic:

**THONGLOUN SISOULITH**
Prime Minister

For Malaysia:

**DATO' SRI MOHD NAJIB TUN ABDUL RAZAK**
Prime Minister

For the Republic of the Union of Myanmar:

**AUNG SAN SUU KYI**
State Counsellor

For the Republic of the Philippines:

**RODRIGO ROA DUTERTE**
President

For the Republic of Singapore:

**LEE HSIEN LOONG**
Prime Minister

For the Kingdom of Thailand:

**GENERAL PRAYUT CHAN-O-CHA (RET.)**
Prime Minister

For the Socialist Republic of Viet Nam:

**NGUYEN XUAN PHUC**
Prime Minister